# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

១៦-៣-២០០៥ -ព្រះរាជក្រម នស/រកម/០៣០៥/០០៥ ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី ១៧៤៨

១៦-៣-២០០៥ -ព្រះរាជក្រម នស/រកម/០៣០៥/០០៦ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពី បត្យាប័ន ១៧៥០

### ២~ព្រះរាជក្រឹត្យ

០៣-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១១០ ស្តីពីការតែងតាំងមន្ត្រីរាជការ ចំនួន ០៤ រូប ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឬទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ១៧៥២

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៥ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនឯកឧត្តម អស់លោក លោកស្រី ចំនួន ២០ រូប ១៧៥៣

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣២ ស្តីពីការតែងតាំង ឯកឧត្តម **ម៉ម សារិន** ជានាយខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ១៧៥៥

១៦-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣៣ ស្តីពីការលុបឈ្មោះ ឯកឧត្តម **ឌូ ឌុន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១៧៥៦

១៦-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣៤ ស្តីពីការផ្ទេរក្របខ័ណ្ឌលោក **អៀង អូនលី** អនុមន្ត្រីថ្នាក់លេខ ១៤ ពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃទៅបំរើការ នៅទីស្តីការគណៈរដ្ឋមន្ត្រីក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ១៧៥៧

១៦-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣៥ ស្តីពីការកែសំរួល មាត្រា ១ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៣/១៥៦ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពី ការតែងតាំងប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក គណៈកម្មាធិការទទួល ស្គាល់គុណភាពអប់រំនៃកម្ពុជា ១៧៥៨

១៦-៣-២០០៥ -ព្រះរាជក្រឹត្យនស/រកត/០៣០៥/១៣៦ស្តីពីការតែងតាំងឯកឧត្តម **ចាន់ គីស៊ីម** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅ សាធារណរដ្ឋប៉ូឡូញ និងជាឯកអគ្គរាជទូតតែងតាំង នៅសាធារណរដ្ឋឆែក ស្លូវ៉ាគ និង ហុងគ្រី ១៧៦០

២១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៥៤ ស្តីពីការប្រគល់ភារកិច្ច និង តែងតាំង មន្ត្រីរាជការ ១៧៦១

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

២៣-៣-២០០៥ -លិខិតលេខ ០៥/២០០៥ កបធ.សជណ ស្តីពីបណ្តឹងរបស់លោក **ខែម ចាសនា** លេខ ០០២៤ គសចជន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ ១៧៦២

## III~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពី ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន ១៧៦៣

១៦-៣-២០០៥ -អនុក្រឹត្យលេខ ២៩២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៧៨៤

១៦-៣-២០០៥ -អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៧៨៥

១៦-៣-២០០៥ -អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៨៦

១៦-៣-២០០៥ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៧៨៧

១៦-៣-២០០៥ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៧៨៨

១៦-៣-២០០៥ -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៨៩

១៧-៣-២០០៥ -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨០១

១៧-៣-២០០៥ -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨០២

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៨០៣

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨០៤

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨០៦

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨០៧

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨០៨

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨០៩

១៧-៣-២០០៥ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨១១

១៨-៣-២០០៥ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨១២

១៨-៣-២០០៥ -អនុក្រឹត្យលេខ ៣០៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១៨១៤

២១-៣-២០០៥ -អនុក្រឹត្យលេខ ៣០៩ អនក្រ.តត ស្តីពី ការបន្ថែមក្របខណ្ឌមន្ត្រីនគរបាលជាតិ ១៨១៥

២១-៣-២០០៥ -អនុក្រឹត្យលេខ ៣១០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨១៦

២១-៣-២០០៥ -អនុក្រឹត្យលេខ ៣១១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨១៨

២១-៣-២០០៥ -អនុក្រឹត្យលេខ ៣១២ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ ១៨១៩

២១-៣-២០០៥ -អនុក្រឹត្យលេខ ៣១៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨២១

២២-៣-២០០៥ -អនុក្រឹត្យលេខ ៣១៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨២២

២២-៣-២០០៥ -អនុក្រឹត្យលេខ ៣១៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨២៤

២៣-៣-២០០៥ -អនុក្រឹត្យលេខ ៣១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨២៥

## IV~ការងារបណ្តាក្រសួង

## ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២១-៣-២០០៥ -ប្រកាសលេខ ១១៩ MOC/M2005 ស្តីពីការតែងតាំងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ១៨២៦

២១-៣-២០០៥ -ប្រកាសលេខ ១២០ MOC/M2005 ស្តីពីស្ថានភាពរោងចក្រកាត់ដេរ SAM HAN CAMBODIA FABRIC CO.,LTD. ១៨២៨

២១-៣-២០០៥ -PRAKAS Nº120 MOC/M2005 On The Status of SAM HAN CAMBODIA FABRIC CO.,LTD. in Cambodia ១៨៣០

០៩-៣-២០០៥ -លិខិតលេខ ៥៥៨ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អូរៀន ថល ប្លាស ខូ អិលធីឌី** ១៨៣២

១០-៣-២០០៥ -លិខិតលេខ ៥៥៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សុគន្ធិ នីកា អ៊ិនវេសមេន អាប្រ្លោ-អ៊ិនដាសស្រ្ទៀល ផ្លេន** ១៨៣៤

១៤-៣-២០០៥ -លិខិតលេខ ៥៦២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេម បូឌាន ជុង ឈាង គ្រេដ ខូ អិលធីឌី** ១៨៣៦

១៤-៣-២០០៥ -លិខិតលេខ ៥៦៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សល សុគា ពាណិជ្ជ** ១៨៣៨

១៥-៣-២០០៥ -លិខិតលេខ ៥៨១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ៊ុយ ហុង អ៊ិមផត អិចផត** ១៨៤០

១៥-៣-២០០៥ -លិខិតលេខ ៥៨២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ី ធី អេស** ១៨៤២

១៥-៣-២០០៥ -លិខិតលេខ ៥៨៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **តិកនីច ហូលឌីង** ១៨៤៤

១៦-៣-២០០៥ -លិខិតលេខ ៥៩៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **យូនីវើសល អ៊ែរ ស៊ើវិស អ៊ិន** ១៨៤៦

១៦-៣-២០០៥ -លិខិតលេខ ៥៩៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **មិក អ៊ិនធើណេសិនណល គ្រេឌីង** ១៨៤៨

១៧-៣-២០០៥ -លិខិតលេខ ៦១៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ី.អេស.ទ៉ាយ ស្លាយ ស្តូន** ១៨៥០

១៧-៣-២០០៥ -លិខិតលេខ ៦១៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឆាយអើដឹម អ៊ិនវេសមេន គ្រុប** ១៨៥២

១៧-៣-២០០៥ -លិខិតលេខ ៦១៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **(ខេមបូឌា) មេឌីយ៉ា តីធីអ៊ី អិលធីឌី** ១៨៥៤

១៧-៣-២០០៥ -លិខិតលេខ ៦១៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេ ស៊ី អេ គ្រេឌីង** ១៨៥៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៦២ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ី ធី អេស**

**C T S Co.,Ltd.**

**( CAMBODIA TRANSPORTATION SERVICES )**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7537/05P ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឃួត ប៊ុរិន្ទ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១១៥ ផ្លូវលេខ ១៤៤ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវា[illegible]

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌល[illegible]

# ព្រះរាជក្រម

នស/រកម/០៣០៥/០០៥

## យើង

## ព្រះករុណាព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានៅទីក្រុងប៉ារីស នាថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.០៥០៣.០០៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ហត្ថលេខា**

**ទៀ បាញ់ ញឹក ប៊ុនឆៃ**

លេខ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible]**

# ព្រះរាជក្រម

នស/រកម/០៣០៥/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សត្តខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពីបត្យាប័នដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ស្តីពី
## ការអនុម័តយល់ព្រមលើសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពីបត្យាប័ន

**មាត្រា ១.-**

អនុម័តយល់ព្រមលើសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពីបត្យាប័ន ដែលបានចុះហត្ថលេខានៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.០៥០៣.១៤៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
**ហត្ថលេខា**
**ហោ ណាំហុង**

លេខ ៖ ១០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៥ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

១- លោក មាស សូលីតន្ធា ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

២- លោក យ៉ង់ ស៊ុំ ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៣- លោក អ៊ិន សុផល ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៤- លោក ជា សុឃួន ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពរស.០៥០៣.១១៣*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៥*

លេខ : ៦១៥ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

[illegible] តាន់

នស/រកត/០៣០៥/១២៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានទទួលការប្រោសប្រទាននូវគ្រឿង ឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម អស់លោក លោកស្រី ចំនួន ២០ រូប ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ :

១- ឯកឧត្តម **នុត សាអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះ :

១- លោកឧកញ៉ា **ទីត ជូរ** ប្រធានក្រុមហ៊ុនសំណង់ភ្នំពេញ

២- លោក **ឃោ កាន់** អភិបាលរងខេត្តកណ្តាល

៣- លោក **អ៊ុខ ឆ័ន** អភិបាលរងខេត្តឧត្តរមានជ័យ

៤- លោក **ឡេខ ឈឿខ** អភិបាលរងក្រុងកែប

៥- លោក ម៉ែន ម៉ុនមុល ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៦- លោក ពេជ សុភត្ត អនុប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៧- លោក សោម ទាន់ជា អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៨- លោក សុខ សារ៉េត អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន

៩- លោក ឈាង ធិរេចនៈ អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន

១០- លោក គុយ ម៉ុនសន អនុប្រធាននាយកដ្ឋានពន្ធនាគារ

១១- លោក ជុន ម៉ុនចាល់ អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ

១២- លោក ឡាយ ណារុទ្ធ អនុប្រធាននាយកដ្ឋានស្ថាបនា

១៣-លោកស្រី សុខ សម្បត្តិ អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន

១៤-លោកស្រី ញុំ ចន្ថា អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល

១៥- លោក អ៊ុយ ស៊ុន ប្រធានការិយាល័យគណនេយ្យ

១៦- លោក សេខ ឈួន ប្រធានកំពង់ចម្លងអ្នកលឿង

១៧- លោក ទាន់ ចន ប្រធានមន្ទីរធនធានទឹកខេត្តព្រៃវែង

១៨- លោក ញុំ សុធា មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

១៩- លោក ចន ខូត ប្រធានអង្គការ CCFC

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៥០៣.១៧៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០០៥

លេខ : ១១៣ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាវី តាន់

44

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៧២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម ម៉ម សារិន ជានាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** រាល់បទបញ្ញត្តិណាដែលផ្ទុយ នឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយក ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
**សុខ ឥសាន់**

៣៧ល.០៥០៣.១៣៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៣៣

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលុបឈ្មោះ ឯកឧត្ដម ឆូ ឆុន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ២** : សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា តទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

ពរស.០៥០៣.១៣៦

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥

**ឈាង តាន់**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៣៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២១១ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល នៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានផ្ទេរក្របខ័ណ្ឌ លោក សៀង អូនសី អនុមន្ត្រីថ្នាក់លេខ ១៤ ពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅបំរើការងារនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស-០៥០៣-១៣៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០៥

២/២

នស/រកត/០៣០៥/១៣៥

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកែសម្រួល មាត្រា១ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៣/១៩១ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំង ប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត/០៦០៣/១៩១ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំង ប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/១៩១ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៣ ស្តីពីការតែងតាំង ប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិក គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវបានកែសម្រួល ដូចខាងក្រោម :

**មាត្រា១ ថ្មី.-**

តែងតាំងជាប្រធាន និង អនុប្រធាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា នូវឥស្សរជនដែលមាននាមដូចខាងក្រោម÷

១- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២- ឯកឧត្តម **គុល ផេង** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី .-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រាបួន .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នរក-០៥០៣-១៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០៥

លេខ ១១៦ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា - ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាន់ តាន់



3/3

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម **ចាន់ គីស៊ីម** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណរដ្ឋប៉ូឡូញ និងជាឯកអគ្គរាជទូតតែងតាំង នៅសាធារណរដ្ឋឆែក ស្លូវ៉ាគ និង ហុងគ្រី ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៣.១៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០៥

បានឃើញ ចម្លងត្រឹមត្រូវ ដ.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ០៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ស៊ីម តាន់**

3/2

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ម៉ក់ ថារិន** ឱ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំយុវជន និងកីឡា ។

**មាត្រា ២:** ត្រូវបានផ្ទេរភារកិច្ចឯកឧត្តម **ឆយ អុន** ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំយុវជន និងកីឡា និងតែងតាំងឯកឧត្តម **ឆយ អុន** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ៣:** ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា :

១- ឯកឧត្តម **សយ ញៀន** ឱ្យបំពេញមុខងារជាអគ្គាធិការនៃអគ្គាធិការដ្ឋាន
២- ឯកឧត្តម **ឡាក់ សំអាត** ឱ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន និងកីឡា
៣- ឯកឧត្តម **ជា អៀង** ឱ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
៤- ឯកឧត្តម **ឡៅ ឈឹមអៀង** ឱ្យបំពេញមុខងារជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

**មាត្រា ៤:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល-០៥០៣.១៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០០៥

ច្បាប់ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សៅ ចាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៥/២០០៥ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥

**ជូនចំពោះ**

**លោក ខែម សាសនា**

**កម្មវត្ថុ** : បណ្តឹងរបស់លោកលេខ ០០២៤ គសចជន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

ដូចកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកថា ក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា បណ្តឹងរបស់លោកលេខ ០០២៤ គសចជន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ មិនអាចយកមកពិនិត្យបានទេ ពីព្រោះបណ្តឹងនេះមិនស្របនឹងវាក្យខ័ណ្ឌទី១នៃមាត្រា ២៥ ជំពូកទី៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ដែលចែងថា " *គណបក្សនយោបាយ ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។* " និងមាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

អគារ "ក" វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : (០២៣) ៧២៦ ០៣០ ឬ (០២៣) ៧២៦ ០៣៤ ហ្វាក់ (៨៥៥) ២៣ ៧២០ ៩១៣ អ៊ីមែល : sgcc@camnet.com.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៤ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញព្រះរាជក្រមលេខ នស / រកម /១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- យោងខ្លឹមសារអនុសញ្ញា ទីក្រុងវីយែន ស្តីពីកិច្ចការពារស្រទាប់ អូហ្សូន និងពិធីសារ ម៉ុងរ៉េអាល់ ស្តីពីសារធាតុ ដែលបំផ្លាញស្រទាប់ អូហ្សូន ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាចូលជាសមាជិក ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០១
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៥ ។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលបំណង កំណត់ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន (Ozone Layer) និងការគ្រប់គ្រងសកម្មភាពអាជីវកម្ម និងការប្រើប្រាស់សារធាតុនេះ ស្របតាមពិធីសារ ម៉ុងរ៉េអាល់ នៃអនុសញ្ញា ទីក្រុងវីយ៉ែន ។

**មាត្រា ២ .-**

អនុក្រឹត្យនេះអនុវត្តចំពោះរាល់ការនាំចូល ការនាំចេញ ការឆ្លងកាត់ ការផលិត ការស្តុកទុក ការលក់ដូរ ការដឹកជញ្ជូន និងការប្រើប្រាស់សារធាតុ ដែលបំផ្លាញស្រទាប់ អូហ្សូន (Ozone Layer) ទោះបីសារធាតុនោះមានលក្ខណៈទោល ឬសមាស នៅរក្សាភាពដើម ប្រើប្រាស់រួចហើយ ចំរាញ់ឡើងវិញ ឬក៏ធ្វើការកែប្រែគុណភាពក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។

**មាត្រា ៣ .-**

ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ៖

ក- **ស្រទាប់ អូហ្សូន** (Ozone Layer) សំដៅដល់ ឧស្ម័នអូហ្សូន($O_3$) ដែលប្រមូលផ្តុំស្ថិតនៅក្នុងបរិយាកាសតាមបែបធម្មជាតិ មានកម្ពស់ប្រហែល ៥០ គីឡូម៉ែត្រពីផែនដី ហើយមានបរិមាណប្រហែល ៩០ ភាគរយ នៃបរិមាណអូហ្សូនសរុបនៅលើផែនដី ។

ខ- **សារធាតុបំផ្លាញស្រទាប់ អូហ្សូន** (Ozone Layer) សំដៅដល់សារធាតុគីមី ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទាំងឡាយ ដែលមានឥទ្ធិពលប៉ះពាល់ចំពោះម៉ូលេគុលអូហ្សូន (Ozone) រួមមាន**សារធាតុ ក្លរ៉ូ-ភ្លុយអរ៉ូកាបូន** [Chlorofluorocarbons (CFCs)] **សារធាតុ ហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន** [Hydrochlorofluorocarbons (HCFCs)] **សារធាតុ មេទីលក្លរ៉ូហ្វម** (Methyl chloroform) **ហាឡូន** (Halon) **សារធាតុ កាបូនតេត្រាក្លរ៉ាយ** (Carbon tetrachloride) **សារធាតុ មេទីលប្រូម៉ាយ** (Methyl bromide) ឬសារធាតុ ទាំងឡាយដែលមានល្បាយសារធាតុ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

គ- **ផលិតផល** សំដៅដល់ផលិតផលទាំងឡាយ ដូចបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ឬឧបសម្ព័ន្ធ D នៃពិធីសារ ម៉ុងរ៉េអាល់ ដែលមានផ្ទុក ឬដែលត្រូវគេបង្កើតឡើងដើម្បីប្រើប្រាស់សារធាតុ CFCs និងហាឡូន ។

# ជំពូកទី ២
# ការនាំចូល ការនាំចេញ និងបែបបទសម្រាប់ការចុះបញ្ជី

**មាត្រា ៤ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ត្រូវចុះបញ្ជីនៅក្រសួងបរិស្ថាន ដើម្បីទទួលលិខិតអនុញ្ញាត ។ ចំពោះផលិតផល ដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះតម្រូវឱ្យគ្រាន់តែចុះបញ្ជីនៅក្រសួងបរិស្ថានប៉ុណ្ណោះ ។

**មាត្រា ៥ ._**

ការស្នើសុំលិខិតអនុញ្ញាតនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន លើកលែងតែសារធាតុ ហាយដ្រូក្លរ៉ូផ្លុយអរ៉ូកាបូន (HCFCs) ត្រូវធ្វើឡើងមិនឱ្យហួសពីហុកសិបថ្ងៃ (៦០ថ្ងៃ) បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន និងត្រូវធ្វើឱ្យបានមុនថ្ងៃទី ០១ ខែវិច្ឆិកា សម្រាប់ឆ្នាំបន្តបន្ទាប់ ។ ក្រសួងបរិស្ថានត្រូវធ្វើការសម្រេចលើពាក្យស្នើសុំ មិនឱ្យហួសពីថ្ងៃទី ០១ ខែធ្នូ ។

**មាត្រា ៦ ._**

ម្ចាស់សំណើត្រូវដាក់ពាក្យសុំនាំចូល សារធាតុ ហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន (HCFCs) ជូនក្រសួងបរិស្ថានពិនិត្យរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនការនាំចូល ។

ក្រសួងបរិស្ថានត្រូវធ្វើការពិនិត្យ និងសម្រេច ចុះបញ្ជីមិនឱ្យលើសពីប្រាំពីរថ្ងៃ (០៧ថ្ងៃ) បន្ទាប់ពីបានទទួលការស្នើសុំ ។

**មាត្រា ៧ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបានចុះបញ្ជី និងបានទទួលលិខិតអនុញ្ញាតនាំចូល ត្រូវជូនដំណឹងទៅក្រសួងបរិស្ថាន ក្រោយពេលនាំចូលនីមួយៗ ។ ក្រោយពេលនាំចូល រាល់ប្រដាប់សម្រាប់ដាក់ដែលមានផ្ទុកសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវតែមានបិទផ្លាកសញ្ញារបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨ ._**

ផលិតផលដែលមានផ្ទុក ឬប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុង ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ត្រូវហាមឃាត់ដាច់ខាតក្នុងការនាំចូល ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៦ ។

សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ត្រូវហាមឃាត់ដាច់ខាតក្នុងការនាំចូលចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ ។

**មាត្រា ៩ .-**

ករណីលើកលែងពិសេស នឹងត្រូវបានអនុវត្តក្នុងការអនុញ្ញាតនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន និងផលិតផលដូចខាងក្រោម ៖

១- សារធាតុ ហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន (HCFCs) អាចអនុញ្ញាតឱ្យនាំចូលរហូតដល់ឆ្នាំ២០៤០ ។

២- ម៉េទីលប្រូម៉ាយ ដែលប្រើប្រាស់សម្រាប់បំបាត់កត្តាចង្រៃមុនការរៀបចំដឹកជញ្ជូន ។

៣- ផលិតផលឱសថ ដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ក្នុងវិស័យសុខាភិបាល ។

៤- ហាឡូន ដែលប្រើប្រាស់ក្នុងការពន្លត់អគ្គិភ័យក្នុងវិស័យអាកាសចរណ៍ ។

៥- សារធាតុបំផ្លាញស្រទាប់ អូហ្សូន និងផលិតផលផ្សេងៗទៀត ដែលចេញប្រកាសដោយក្រសួងបរិស្ថានស្របតាមសេចក្តីសម្រេចអង្គប្រជុំភាគី នៃពិធីសារ ម៉ុងរ៉េអាល់ ។

**មាត្រា ១០ .-**

ការនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន ឬផលិតផល ដូចមានបញ្ជាក់នៅក្នុងតារាង ឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ពីប្រទេសដែលមិនមែនជាសមាជិក នៃពិធីសារ ម៉ុងរ៉េអាល់ ត្រូវបានហាមឃាត់ ។ ក្រសួងបរិស្ថានត្រូវជូនដំណឹងអំពីប្រទេសដែលមិនមែនជាសមាជិកពិធីសារ ម៉ុងរ៉េអាល់ នៃអនុសញ្ញា ទីក្រុងវីយែន ។

**មាត្រា ១១ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងនាំចេញសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវដា ក់ពាក្យស្នើសុំទៅក្រសួងបរិស្ថានឱ្យបានមុនដប់ប្រាំថ្ងៃ ( ១៥ ថ្ងៃ) នៃការនាំចេញ ដើម្បីធ្វើការចុះបញ្ជី និងពិនិត្យសម្រេច ។

## ជំពូកទី ៣
## ការត្រួតពិនិត្យ ការធ្វើអាជីវកម្ម
## និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ១២ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបាន និងកំពុង ឬមានបំណងដាក់លក់ លក់ ស្តុក ចែកចាយ ឬប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវធ្វើការកត់ត្រាឱ្យបានច្បាស់លាស់នូវបរិមាណ និងប្រភេទសារធាតុ ដែលលក់បានប្រចាំថ្ងៃ ដើម្បីងាយស្រួលដល់ការធ្វើអធិការកិច្ចរបស់ស្ថាប័នមានសមត្ថកិច្ច ។

រាល់ប្រដាប់សម្រាប់ដាក់ដែលមានផ្ទុកសារធាតុបំផ្លាញស្រទាប់ អូហ្សូន ទាំងអស់មុននឹងយកទៅលក់ ឬចែកចាយត្រូវតែមានបិទផ្លាកសញ្ញាសម្គាល់ដែលចេញដោយក្រសួងបរិស្ថាន ។

**មាត្រា ១៣ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលបាន និងកំពុងប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន នៅក្នុងដំណើរការផលិតកម្មរបស់ខ្លួន ត្រូវមកធ្វើការចុះបញ្ជីនៅក្រសួងបរិស្ថាន ។ ចំពោះអាជីវកម្មដែលមានស្រាប់ត្រូវមកចុះបញ្ជីយ៉ាងយូរកៅសិបថ្ងៃ (៩០ថ្ងៃ) បន្ទាប់ពីការចូលជាធរមាននៃអនុក្រឹត្យនេះ ។

**មាត្រា ១៤ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងធ្វើការពង្រីក ឬការបង្កើតថ្មី នូវប្រព័ន្ធដែលប្រើប្រាស់សារធាតុ CFCs សម្រាប់ផលិតកម្មក្នុងរោងចក្រ-សហគ្រាសរបស់ខ្លួន ត្រូវហាមឃាត់ជាដាច់ខាត ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥។

**មាត្រា ១៥ ._**

រាល់ការផ្ទេរប្រដាប់សម្រាប់ដាក់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ពីមួយទៅមួយ ត្រូវតែសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

## ជំពូកទី ៤
## ការសំអាតឡើងវិញ ការកែច្នៃ និងការបំផ្លាញចោល សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ១៦ ._**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ : សំអាត សំដៅដល់ការរចនាឡើងវិញ នូវសារធាតុអ្វីមួយ ដែលមានន័យជាភាសាអង់គ្លេសថា Recycle ។

**មាត្រា ១៧ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលណាក៏ដោយ មិនអាចធ្វើការសំអាតឡើងវិញ នូវសារធាតុបំផ្លាញស្រទាប់ អូហ្សូន ដែលបានប្រើប្រាស់រួចហើយ លើកលែងតែមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១៨ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានបំណងធ្វើការបំផ្លាញចោល ឬកែច្នៃ នូវសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវមានឧបករណ៍បច្ចេកទេសដែលទទួលការអនុញ្ញាតពីក្រសួងបរិស្ថាន ដោយរួមសហការជាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

## ជំពូកទី ៥

## ការត្រួតពិនិត្យឧបករណ៍ធ្វើឱ្យត្រជាក់

**មាត្រា ១៩ .-**

សេវាកម្មជួសជុលម៉ាស៊ីនត្រជាក់ ទូទឹកកក ឬ ឧបករណ៍ធ្វើឱ្យត្រជាក់គ្រប់ប្រភេទ មិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរប្រព័ន្ធដែលកំពុងប្រើប្រាស់សារធាតុជំនួស ទៅប្រើប្រាស់សារធាតុ CFCs វិញ ជាដាច់ខាត ។

**មាត្រា ២០ .-**

ការផ្តល់ប័ណ្ណសម្គាល់យានយន្តគ្រប់ប្រភេទ ដែលមានប្រព័ន្ធម៉ាស៊ីនត្រជាក់ប្រើប្រាស់សារធាតុ CFCs ត្រូវហាមឃាត់ដាច់ខាត ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៦ ។

**មាត្រា ២១ .-**

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រងត្រួតពិនិត្យ និងអនុវត្តតាមមាត្រា២០ នៃអនុក្រឹត្យនេះ ។ បែបបទក្នុងការគ្រប់គ្រងត្រួតពិនិត្យ និងអនុវត្តបទប្បញ្ញត្តិ ដូចបានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ នឹងកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៦

## ការលុបបំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ២២ .-**

ការនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវអនុវត្តតាមកម្មវិធីលុបបំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន នៃពិធីសារ ម៉ុងរ៉េអាល់ ដោយយោងតាមកម្រិត នៃការប្រើប្រាស់នៅក្នុង កម្មវិធីជាតិសម្រាប់ការលុបបំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចខាងក្រោម ៖

- ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ : -កម្រិតការប្រើប្រាស់សារធាតុ CFCs នៅក្នុង ឧបសម្ព័ន្ធទី១ ឱ្យនៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។
- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ : -កម្រិតការប្រើប្រាស់សារធាតុ ហាឡូន ឱ្យនៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។
  -កម្រិតការប្រើប្រាស់សារធាតុ មេទីលប្រូម៉ាយ ឱ្យនៅត្រឹមកម្រិតមធ្យមនៃចន្លោះឆ្នាំ១៩៩៥-១៩៩៨ ។
- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣ : -សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី២ ក្រុម១ ត្រូវកាត់បន្ថយ

នៅត្រឹម ២០ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០០ ។

-កម្រិតការប្រើប្រាស់សារធាតុ ម៉េទីលក្លរ៉ូហ្វម ឱ្យនៅត្រឹមកម្រិតមធ្យមនៃចន្លោះឆ្នាំ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ : -សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី១ ត្រូវកាត់បន្ថយនៅត្រឹម ៥០ ភាគរយ នៃការប្រើប្រាស់ជាមធ្យមក្នុងចន្លោះឆ្នាំ ១៩៩៥-១៩៩៨ ។

-សារធាតុ ហាឡូន ត្រូវកាត់បន្ថយនៅត្រឹម ៥០ ភាគរយ ឱ្យនៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។

-សារធាតុ កាបូនតេត្រាក្លរ៉ាយ ត្រូវកាត់បន្ថយនៅត្រឹម ៨៥ ភាគរយ នៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៨-២០០០ ។

-សារធាតុ ម៉េទីលក្លរ៉ូហ្វម ត្រូវកាត់បន្ថយនៅត្រឹម ៣០ ភាគរយ នៃការប្រើប្រាស់ជាមធ្យមក្នុងចន្លោះ ឆ្នាំ ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ : - សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី១ ត្រូវកាត់បន្ថយនៅត្រឹម ៨៥ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។

- សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី២ ត្រូវកាត់បន្ថយនៅត្រឹម ៨៥ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ : - សារធាតុ CFCs ហាឡូន និងកាបូនតេត្រាក្លរ៉ាយ លប់បំបាត់ចោល ។

- សារធាតុ ម៉េទីលក្លរ៉ូហ្វម កាត់បន្ថយនៅត្រឹម ៧០ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ : -សារធាតុ ម៉េទីលក្លរ៉ូហ្វម និង ម៉េទីលប្រូម៉ាយ ត្រូវលប់បំបាត់ចោល ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ : -កម្រិតការប្រើប្រាស់សារធាតុ HCFCs តាមតួលេខជាមូលដ្ឋាន នៃការប្រើប្រាស់ជាមធ្យមនៅក្នុង ឆ្នាំ ២០១៥ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០៤០ : - សារធាតុ HCFCs ត្រូវលប់បំបាត់ចោល ។

# ជំពូកទី ៧

## ការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រង
## សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ២៣ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបាន និងកំពុងធ្វើអាជីវកម្ម ឬមានបំណងនឹងធ្វើអាជីវកម្មសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវបញ្ជូនកំណត់ត្រា និងរបាយការណ៍ ដែលទាក់ទងនឹងការធ្វើអាជីវកម្មប្រចាំឆ្នាំមក ក្រសួងបរិស្ថាន ។

**មាត្រា ២៤ .-**

អង្គភាពទទួលបន្ទុកគ្រប់គ្រងអូហ្សូនជាតិស្ថិតក្រោមក្រសួងបរិស្ថាន មានភារកិច្ចអនុវត្តដូចខាងក្រោមនេះ ៖

- បំពេញតួនាទីជាមជ្ឈមណ្ឌលសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលរបាយការណ៍ ស្តីពីការត្រួតពិនិត្យ ការនាំចូល នាំចេញ ការផលិត និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន
- សម្របសម្រួលការងារជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផែនការលម្អិត កម្មវិធី និងបទដ្ឋានក្នុងការលុបបំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន
- ធ្វើរបាយការណ៍ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការនាំចេញ នាំចូល ការផលិត និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ជូនរាជរដ្ឋាភិបាលកម្ពុជា
- តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិ សម្រាប់លុបបំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន និងធ្វើគម្រោងទាក់ទងនឹងការលុបបំបាត់ចោល សារធាតុបំផ្លាញស្រទាប់ អូហ្សូន
- សម្របសម្រួលជាមួយអង្គការអន្តរជាតិ អង្គការតំបន់ និងផ្នែកអូហ្សូនជាតិ នៃបណ្តាប្រទេសដទៃទៀត ដើម្បីផ្លាស់ប្តូរព័ត៌មាន ការផ្តល់យោបល់អំពីគោលនយោបាយ និងជំនួយការផ្នែកបច្ចេកទេសក្នុងកិច្ចការពារស្រទាប់ អូហ្សូន
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីបច្ចេកទេស អំពីបច្ចេកទេសត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់ អូហ្សូន
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពចំពោះមន្ត្រីបច្ចេកទេស និងផ្នែកឯកជន ពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុជំនួស និងការប្រើប្រាស់ឡើងវិញនៃសារធាតុបំផ្លាញស្រទាប់ អូហ្សូន
- អប់រំ និងលើកកម្ពស់ការយល់ដឹង អំពីសារធាតុបំផ្លាញស្រទាប់ អូហ្សូន ដល់អ្នកពាក់ព័ន្ធទាំងអស់ ដោយធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការចេញបទបញ្ជាដើម្បីបញ្ឈប់ ឬផ្អាកសកម្មភាពទាំងឡាយ ដែលទាក់ទងនឹងសារធាតុបំផ្លាញស្រទាប់ អូហ្សូន នៅពេលណាដែលពិនិត្យឃើញថា សកម្មភាពទាំងនោះបណ្តាលឱ្យមានការប៉ះពាល់ដល់ស្រទាប់ អូហ្សូន

- ធ្វើសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ក្នុងតំបន់ដើម្បីកិច្ចការពារស្រទាប់ អូហ្សូន

**មាត្រា ២៥ .-**

ផែនការសកម្មភាព ស្តីពីការតាមដាន និងការត្រួតពិនិត្យ សារធាតុបំផ្លាញស្រទាប់ អូហ្សូន នៅក្នុងអាជីវកម្មជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ អ្នកផលិត និងអ្នកប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវចូលរួមសហការជាមួយមន្ត្រីត្រួតពិនិត្យតាមការស្នើសុំ ។

ក្នុងករណី ចាំបាច់ការត្រួតពិនិត្យអាចត្រូវធ្វើជាបន្ទាន់ ។

**មាត្រា ២៦ .-**

គំរូពាក្យស្នើសុំចុះបញ្ជី លិខិតអនុញ្ញាត គំរូកំណត់ត្រា ដូចមានចែងនៅក្នុងមាត្រា ៤ ៥ ១១ ១២ និងមាត្រា ១៣ ចេញដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**មាត្រា ២៧ .-**

ក្រសួងបរិស្ថានត្រូវចេញសេចក្តីព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលល្មើសនឹងមាត្រា ១២ ១៣ ១៥ ១៧ ១៨ ១៩ និងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

ក្នុងករណីចចេសរឹងរូស ឬមិនព្រមអនុវត្តតាម ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិ នៃ មាត្រា ២១ ជំពូកទី ៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ២៨ .-**

ជនណាដែលល្មើសនឹងមាត្រា៨ ១០ និងមាត្រា១៤ នៃអនុក្រឹត្យនេះ ឬមិនអនុញ្ញាត ឬរាំងមន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថានធ្វើការត្រួតពិនិត្យ ឬបំពេញបេសកកម្មរបស់ខ្លួនក្នុងការអនុវត្តអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា២១ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២៩ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣០
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យ
# លេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៥
# ស្តីពី ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

## តារាងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

| ឈ្មោះ/ក្រុម | ឈ្មោះគីមី | រូបមន្ត | និមិត្តសញ្ញា | លេខកូដ | សក្តិសិទ្ធិពលបំផ្លាញ អូហ្សូន |
|---|---|---|---|---|---|
| | **Halogenated derivatives of hydrocarbons** | | | | |
| ផ្នែក ក ក្រុមទី ១ (CFC) | **Halogenated derivatives of acyclic hydrocarbons containing two or more different halogens** | | | | |
| CFC-11 | Trichlorofluoromethane | $CFCL_3$ | R-11 | 2903.41.00 | 1.0 |
| CFC-12 | Dichlorodifluoromethane | $CF_2CL_3$ | R-12 | 2903.42.00 | 1.0 |
| CFC-113 | Trichlorotrifluoroethane | $C_2F_3CL_3$ | R-113 | 2903.43.00 | 0.8 |
| CFC-114 | Dichlorotetrafluoroethanes | $C_2F_4CL_2$ | R-114 | 2903.44.00 | 1.0 |
| CFC-115 | Chloropentafluoroethane | $CCLF_2CF_3$ | R-115 | 2903.44.00 | 0.6 |
| ផ្នែក ក ក្រុមទី ២ (Halon) | **Halogenated derivatives of acyclic hydrocarbons containing two or more different halogens** | | | | |
| Halon-1211 | Bromochlorodifluoromethane | $CF_2BrCL$ | R-12B1 | 2903.46.00 | 3.0 |
